


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ឆាំង យុ

## ចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ ឆ្នាំ២០១៧ ដល់ឆ្នាំ២០២០

មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមើលមើលអំពីអនាគតថ្មីមួយសម្រាប់ប្រទេសកម្ពុជា។កម្ពុជាបានខ្នះខ្នែងអស់រយៈជាច្រើនទសវត្សរ៍ដើម្បីធ្វើជាម្ចាស់លើអតីតកាលរបស់ខ្លួន មិនត្រឹមតែនៅក្នុងកម្រិតបុគ្គល និងសហគមន៍តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងកម្រិតជាស្ថាប័នទៀតផង ក្នុងនោះរួមមាន សង្គមស៊ីវិល វប្បធម៌ និងសាសនា។ អន្តរកាលបែបនេះគឺមិនមានភាពងាយស្រួលនោះទេ។ អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅទ្រង់ទ្រាយធំបង្កផលប៉ះពាល់ដល់សង្គមជាតិជាច្រើនជំនាន់។ ប៉ុន្តែ សង្គមក្រោយជម្លោះក៏មិនចាំបាច់សុទ្ធតែត្រូវភ្ជាប់ខ្លួនទៅនឹងអតីតកាលរបស់ខ្លួនទាំងអស់នោះទេ។ ប្រជាជនដែលសកម្មអាចទាញយកឥទ្ធិពលល្អៗសម្រាប់ស្ថានភាពទិសដៅ និងអនាគតរបស់ខ្លួន។ ថ្ងៃថ្មីនីមួយៗនាំមកនូវឱកាសថ្មីៗក្នុងការរីកលូតលាស់ និងដុះដាល ល្ពឹកណាបុគ្គល សហគមន៍ និងប្រទេសជាតិ បានដឹង និងទទួលបានឱកាសក្នុង ការពិភាក្សា និងផ្សះផ្សាខ្លួនផ្ទាល់ទៅនឹងអតីតកាល។

ប្រទេសមួយត្រូវតែប្រឈមមុខនឹងអតីតកាលរបស់ខ្លួន ប្រសិនបើប្រទេសនោះចង់ធ្វើដំណើរទៅមុខទៀត។ នេះគឺជាការតស៊ូមួយដែលរាល់សង្គមក្រោយជម្លោះទាំងអស់ត្រូវឆ្លងកាត់ ដោយមិនគិតពីនយោបាយ វប្បធម៌ ឬស្ថានភាពបែបណាមួយនោះទេ។ ជារួម ដើម្បីឆ្ពោះទៅមុខ យើងត្រូវតែធ្វើការស្រាវជ្រាវយ៉ាងមោះមុតអំពីអតីតកាលរំព្ញកពីសមិទ្ធិផលរបស់មនុស្សជាតិ ការពលី និងការអត់ធន់ ព្រមទាំងស្រាវជ្រាវក៏ដូចជាសិក្សាពីកំហុស បរាជ័យ និងអំពើអាក្រក់របស់មនុស្សជាតិ។

## កម្ពុជា មិនអាចគេចវេះ ពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ប៉ុន្តែកម្ពុជាក៏មិនចាំបាច់ស្ថិតនៅជាទាសករនៃប្រវត្តិសាស្ត្ររបស់ខ្លួនឯងនោះដែរ។ - *ឆាំង យុ*

នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាស្ថិតក្រោមការដឹកនាំនៃរបបប្រល័យពូជសាសន៍ដ៏ព្រៃផ្សៃមួយ នោះគឺរបបកម្ពុជាប្រជាធិបតេយ្យ ដែលដឹកនាំឡើងដោយខ្មែរក្រហម។ ខ្មែរក្រហមបានផ្សព្វផ្សាយអំពីការរើសអើងពូជសាសន៍ ការបំផុសឲ្យស្អប់ជនបរទេស និងការគាបសង្កត់ផ្តាច់ការ ក្នុងគោលបំណងធ្វើឲ្យអំពើឃោរឃៅទ្រង់ទ្រាយធំដ៏ព្រៃផ្សៃក្លាយទៅជាស្របច្បាប់។ ប្រជាជនទីក្រុង បញ្ញវន្ត និងអ្នកមានទ្រព្យធន ត្រូវបានចាត់ទុកជាសត្រូវនៃរបបនេះ។ ជនជាតិវៀតណាម ខ្មែរឥស្លាម និងជនជាតិដទៃទៀតត្រូវបានចាត់ទុកជាសត្រូវដែលជាប់សង្ស័យ។ ក្រុមសង្គម វប្បធម៌ និងសាសនារបស់ជនជាតិភាគតិច ត្រូវបានប្រមូលផ្តុំឲ្យបំពេញការងារធ្ងន់ធ្ងរនៅក្នុងការដ្ឋានលុតដំ ជាទីតាំងដែលអ្នកទាំងនេះត្រូវបានបង្អត់អាហារ រងទុក្ខបុកម្នេញ និងភាគច្រើនត្រូវបានសម្លាប់។

ក្នុងអំឡុងពេលប្រមាណសែសិបខែ ប្រជាជនកម្ពុជាជាងពីរលាននាក់បានបាត់បង់ជីវិតដោយសារតែ ការធ្វើការងារហួសកម្លាំង ការបង្អត់អាហារទ្រង់ទ្រាយធំ ការធ្វើទារុណកម្ម និងការសម្លាប់រង្គាលក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀតដែលធ្វើឡើងដោយរបបខ្មែរក្រហម។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ស្មើភាពជ្រុលនិយមរបស់លទ្ធិកុម្មុយនីស្ត របបនេះបានប្រែក្លាយប្រទេសទាំងមូលឲ្យទៅជាការដ្ឋានពលកម្មធ្ងន់ធ្ងរបំផុត។ ចំពោះអ្នកដែលមិនបានស្លាប់ដោយសារការសម្លាប់ ត្រូវបានបាត់បង់ជីវិតដោយសារតែផលប៉ះពាល់ដែលអូសបន្លាយ ក្នុងនោះរួមមានភាពអត់ឃ្លាន ជំងឺ និងការខ្សោះកម្លាំង។ ជំងឺផ្លូវចិត្តដ៏តឹងតែងនៅតែបន្តដក់ជាប់នៅក្នុងចិត្តនៃជំនាន់មនុស្សដែលរស់នៅក្នុងសម័យកាលនៃឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំនេះ។ អ្នករស់រានមានជីវិតជាច្រើននៅតែ



ចៃ្មត្បិតបានឆ្លងកាត់សង្គ្រាម អំពើប្រល័យពូជសាសន៍ និងទុក្ខវេទនាអស់ជាច្រើនទសវត្សរ៍ កម្ពុជានៅតែមិនបាត់បង់ស្មារតីក្នុងការរស់នៅ ព្រមទាំងមានភាពមោះមុតចំពោះអនាគតដ៏ប្រសើរ។ ការតស៊ូនេះនៅមិនទាន់ចប់នៅឡើយទេ។ នេះគ្រាន់តែជាការចាប់ផ្តើមតែប៉ុណ្ណោះ។ អនាគតរបស់កម្ពុជានឹងមិនត្រឹមតែពឹងផ្អែកលើការត្រិះរិះពិចារណាអំពីអតីតកាលរបស់ខ្លួន ក៏ដូចជាបញ្ហានាពេលបច្ចុប្បន្នតែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវពឹងផ្អែកលើភាពមោះមុតរបស់យើងក្នុងការប្រឈមនឹងភាពលំបាកដែលមាននៅខាងមុខថែមទៀត។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ អ៊ូច មករា។ ការពិពណ៌នា៖ សូ ហ្វារីណា*

មិនបានទទួលព័ត៌មានអំពីសមាជិកគ្រួសារ ឬស្វាមីភរិយារបស់ខ្លួន ដែលបានបាត់ខ្លួននៅក្នុងសម័យកាលកាប់សម្លាប់នេះនៅឡើយ។ ការឈឺចាប់ និងទុក្ខវេទនារបស់អ្នកទាំងនោះ បានបន្តដល់កូនចៅជំនាន់ក្រោយរបស់ខ្លួនដែលបានសួរនាំឪពុកម្តាយអំពីអ្វីដែលបានកើតមានឡើង និងមូលហេតុដែលបណ្តាលឲ្យព្រឹត្តិការណ៍នេះកើតមានឡើង។

បច្ចុប្បន្ន ដំណើរការនីតិវិធីកំពុងត្រូវបានអនុវត្តនៅតុលាការខ្មែរក្រហម បញ្ជាក់អំពីការតស៊ូរបស់កម្ពុជា ក្នុងការប្រឈមនឹងប្រវត្តិសាស្ត្រដែលពោរពេញដោយវិវាទរបស់ខ្លួន។ នៅក្នុងឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងមួយដើម្បីបង្កើត តុលាការខ្មែរក្រហម ដែលមានបេសកកម្មកាត់ទោសជនដៃដល់ ចំពោះឧក្រិដ្ឋកម្មដែលមេដឹកនាំជាន់ខ្ពស់បានធ្វើឡើង នៅក្នុងអំឡុងរបបខ្មែរក្រហម។ តុលាការខ្មែរក្រហមកំពុងធ្វើដំណើរឆ្ពោះទៅកាន់ការបង្កើតនូវកំណត់ត្រាប្រវត្តិសាស្ត្រ ស្តីពីអ្វីដែលបានកើតឡើង និងមូលហេតុអ្វីដែលបណ្តាលឲ្យព្រឹត្តិការណ៍នេះកើតមានឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម សកម្មភាពនេះធ្វើឡើងទៅបាន ដោយសារតែការតស៊ូ និងការចូលរួមរបស់ប្រជាជនកម្ពុជា។ តុលាការនេះត្រូវបានរំខានដោយឧបសគ្គជាច្រើន ដូចជា ហិរញ្ញវត្ថុ ភាពស្របច្បាប់ អំពើពុករលួយ និងភាពមិនចុះសម្រុងផ្ទៃក្នុង ឧទាហរណ៍ដ៏មានថាមពលបំផុតអំពីការតស៊ូនេះ គឺការប្រឈមទៅនឹងអតីតកាលរបស់បុគ្គលម្នាក់ៗ និងការនាំយកឧក្រិដ្ឋជន នៃអំពើឃោរឃៅទ្រង់ទ្រាយធំមកកាត់ទោស ដើម្បីស្វែងរកយុត្តិធម៌បន្ទាប់ពីរយៈពេលជាងបួនទសវត្សរ៍កន្លងផុតទៅ។ មកទល់ពេលបច្ចុប្បន្ន តុលាការនេះបានបញ្ចប់សវនាការរបស់មេដឹកនាំមន្ទីរសន្តិសុខស-២១ និងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហម ទាំងដំណើរការ និងការវិនិច្ឆ័យ ដែលមានសារៈសំខាន់ជានិមិត្តរូបដ៏ធំធេង ចំពោះការតស៊ូរបស់កម្ពុជាក្នុងការយល់ដឹងអំពីសម័យកាល



រូបថតអ្នកទោសខ្មែរក្រហមនៅមន្ទីរស-២១ ដែលមានស្លាកសម្គាល់លេខ៣ ឈ្មោះ ពេញ លាងអូន។ រូបថតនេះត្រូវបានប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយ នួន ម៉ាលី នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២។ យោងតាមទិន្នន័យប្រវត្តិរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (I09310) ពេញ លាងអូន គឺជាស្ត្រីវ័យក្មេងម្នាក់ដែលធ្វើការនៅរោងចក្រក្រណាត់ (T3)។ ពេញ លាងអូន គឺជាប្រធានផ្នែកនៃរោងចក្រក្រណាត់នេះ។ ពេញ លាងអូន ត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦ ហើយបន្ទាប់មកត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានរក្សាទុកនូវប្រវត្តិរូបប្រមាណ ១ម៉ឺន២ពាន់។ ប្រវត្តិរូបជាច្រើនត្រូវបានកត់ត្រាអំពីការឃាត់ខ្លួន និងអ្នកបញ្ជាឲ្យមានការឃាត់ខ្លួនរបស់ជនរងគ្រោះ។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា។*
*ការពិពណ៌នា៖ ឡុង ដានី*

ដ៏ខ្លោចផ្សានេះ។ តុលាការខ្មែរក្រហម នៅមានការងារដ៏មានសារៈសំខាន់ជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សា។

ប្រជាជនកម្ពុជា បន្តតស៊ូជាមួយនឹងកេរដំណែលដ៏រ៉ាំរ៉ៃនៃអំពើប្រល័យពូជសាសន៍ ទារុណកម្ម និងអំពើឃោរឃៅទ្រង់ទ្រាយធំ។ ទោះបីជាអ្នកទាំងនេះសុទ្ធសឹងតែជាប្រជាជនដែលអត់ធន់នឹងភាពលំបាកយ៉ាងណាក្តី ទំនាស់នយោបាយដ៏ជូរចត់នៅតែបន្តបង្កនូវភាពមន្ទិលចំពោះអត្តសញ្ញាណជាតិកម្ពុជាដដែល ទន្ទឹមនឹងនេះ សំណួរនៅតែត្រូវបានបន្តចោទសួរទៅលើផលប៉ះពាល់ និងកេរដំណែលនៃសកម្មភាពយុត្តិធម៌អន្តរកាល។ យើងមិនត្រូវមានការថមថយចំពោះការប្តេជ្ញាដើម្បីយុត្តិធម៌ទេ ព្រោះវាមានសារៈសំខាន់ផ្នែកនយោបាយ និងការអនុវត្ត ម្យ៉ាងទៀត យើងក៏ត្រូវមានភាពជាក់លាក់ចំពោះចក្ខុវិស័យ ព្រមទាំងប្តេជ្ញាជាថ្មីចំពោះភាពជឿនលឿនរបស់យើង បើទោះបីជានៅពេលខ្លះសេចក្តីសង្ឃឹមយ៉ាងមុតមាំ និងការរំពឹងទុករបស់យើងចំពោះស្ថាប័ននយោបាយមិនអាចសម្រេចបានក្តី។ យើងត្រូវតែស្វែងរកឱកាសក្នុងការធ្វើឲ្យពាក្យថា អំពើឃោរឃៅ "មិនអាចកើតមានឡើងជាថ្មីម្តងទៀត" ក្លាយទៅជាទៅការពិត។

នោះមានន័យថា ត្រូវធ្វើឲ្យមានការចូលរួមយ៉ាងសស្រោកសស្រាំជាមួយនឹងស្ថាប័នដែលជាភាគីពាក់ព័ន្ធនៅក្នុងការផ្សះផ្សាជាតិ និងការអភិវឌ្ឍក្រោយជម្លោះ ព្រមទាំងស្វះស្វែងការបើកទូលាយយ៉ាងសកម្មដែលត្រៀមរួចជាស្រេចសម្រាប់ការធ្វើសកម្មភាព។ ជាជាងចុះចាញ់ចំពោះស្ថានភាពហិង្សា គាបសង្កត់ ឬអយុត្តិធម៌ដែលជាផ្នែកនៃលក្ខខណ្ឌរបស់មនុស្ស មជ្ឈមណ្ឌលឯកសារកម្ពុជាជំរុញឲ្យសហគមន៍អន្តរជាតិក្តោបយកឱកាស ដែលគាំពារដោយដំណើរការរបស់តុលាការខ្មែរក្រហម និងដំណើរការដែលស្រដៀងនេះនៅទីកន្លែងដទៃទៀត ដើម្បីសម្របសម្រួលលើសំណួរបន្ថែមអំពីប្រវត្តិសាស្ត្រ និងលើកកម្ពស់ការផ្សះផ្សារវាងអ្នករស់រានមានជីវិតជាមួយនឹងអតីតកាលរួមរបស់គេ។

ការផ្សះផ្សាជាតិទាមទារឲ្យមានការចាប់ផ្តើមឡើងវិញនៃភាសា។ វាតម្រូវឲ្យមានការប្តេជ្ញារបស់បុគ្គលម្នាក់ៗដើម្បីស្វែងរកជាថ្មីនូវភាសាអារ្យធម៌នៃសន្តិភាព ការលើកលែងទោស និងការគោរព។ ភាសាស្អប់ខ្ពើម គំនុំ និងការមិនអត់ឱន ត្រូវតែបោះបង់ចោល ចំណែកភាសាថ្មីសម្រាប់ខ្លួនយើង សហគមន៍ និងអត្តសញ្ញាណជាតិត្រូវតែបង្កើតឡើង។ សរុបមក ការចាប់ផ្តើមឡើងវិញនៃភាសាគឺស្មើនឹងការផ្លាស់ប្តូរវប្បធម៌។ ការផ្លាស់ប្តូរវប្បធម៌គឺមិនអាចសម្រេចបានដោយសារតែការស្រាវជ្រាវអំពីអតីតកាលដែលកែច្នៃ ឬមិនស៊ីជម្រៅ។

សង្គមក្រោយជម្លោះតែងតែតស៊ូទៅនឹងការយល់ដឹងមូលដ្ឋាន ថាតើខ្លួនយើងជានរណា និងថាតើខ្លួនយើងត្រូវបំពេញតួនាទីដោយរបៀបណា។ សូម្បីតែសង្គមក្រោយជម្លោះដែលមានវ័យចំណាស់នៅតែទទួលរងនូវការយល់ឃើញមិនចុះសម្រុងគ្នា។ នៅមានការជំរុញកំបាំងមុខមួយ ឲ្យប្រើប្រាស់អំពើហិង្សា ដើម្បីដោះស្រាយបញ្ហា បើទោះជាសិទ្ធិមនុស្សជាសកលអាចនឹងបង្កើតឲ្យមានការពិភាក្សាជាសាធារណៈ។ ជារួម បញ្ហានេះមិនមែនកើតមានចំពោះតែសង្គមក្រោយជម្លោះតែប៉ុណ្ណោះទេ។ យ៉ាងណាមិញ អ្វីដែលលើកឡើងមុននេះមិនអាចទទួលស្គាល់ថាជាដំណោះស្រាយដែរ វាអាស្រ័យលើអ្នកធ្វើការងារសង្គម ក្នុងការដេញដោលអំពីស្ថាប័ននយោបាយ និងសង្គម ដោយក្នុងនាមជាប្រជាជន និងសកម្មភាព។ សារៈសំខាន់ជាមូលដ្ឋាននោះគឺ សង្គមក្រោយជម្លោះត្រូវការជាខ្លាំងនូវសតិសម្បជញ្ញៈជាតិថ្មីមួយ និងលើសពីនេះទៅទៀត សង្គមស៊ីវិលត្រូវតែដឹកនាំលើកិច្ចការនេះឲ្យបានត្រឹមត្រូវ។

ចាប់តាំងពីការចាប់ផ្តើមក្នុងនាមជាអង្គការសង្គមស៊ីវិល មជ្ឈមណ្ឌលឯកសារកម្ពុជាជាស្ថាប័នដំបូងបង្អស់ ដែលបានចងក្រងឯកសារទាក់ទងនឹងឧក្រិដ្ឋកម្ម និងអំពើឃោរឃៅជាច្រើនអនេក នៅក្នុងរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការផ្តោតលើការប្រមូលចងក្រងភស្តុតាងប្រវត្តិសាស្ត្រពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដើម្បីបង្កើតជាកំណត់ត្រាប្រវត្តិសាស្ត្រ បច្ចុប្បន្ន កិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលបានពង្រីកគម្រោង និងកម្មវិធីទាក់ទងដទៃៗទៀតជាច្រើន ដោយរួមចំណែកក្នុងការកសាងកេរដំណែលយុត្តិធម៌និងការចងចាំ។យុត្តិធម៌និងការចងចាំគឺជាធាតុដ៏ចាំបាច់ជាមូលដ្ឋានសម្រាប់ការផ្សះផ្សា ជាតិ។ យុត្តិធម៌មិនអាចសម្រេចបានដោយមិនធ្វើការចងចាំអំពីជនរងគ្រោះ ឯការចងចាំរបស់ជនរងគ្រោះវិញមិនអាចស្ថិតស្ថេរបានដោយមិនមានការពិតនោះទេ។ យុត្តិធម៌ ការចងចាំ និងការពិត គឺជាគោលគំនិតស្នូលនៃបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងប្រទេសកម្ពុជា។ សមាសធាតុទាំងនេះគឺជាសសរស្តម្ភជានិរន្តរ៍របស់កម្ពុជាក្នុងនាមជាប្រទេសប្រកបដោយសន្តិភាព ភាពចម្រុងចម្រើន និងប្រជាធិបតេយ្យភាព ម្យ៉ាងទៀត ដោយប្រកាន់ខ្ជាប់នូវសមាសធាតុទាំងនេះ នៅទីបំផុត យើងនឹងសម្រេចបានសមិទ្ធិផលនេះ។

នៅរវាងឆ្នាំ២០១៧ និងឆ្នាំ២០២០ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងប្រកាន់ខ្ជាប់នូវបេសកកម្មយូរអង្វែងរបស់ខ្លួនក្នុងការលើកកម្ពស់យុត្តិធម៌ ការចងចាំ និងការផ្សះផ្សា។ យើងនឹងប្រមូលចងក្រងភស្តុតាងជាប្រវត្តិសាស្ត្របន្ថែមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅប្រឆាំងមនុស្សជាតិ ទន្ទឹមនឹងនេះដែរ យើងក៏អប់រំប្រជាជនកម្ពុជាអំពីការពិតនៃប្រវត្តិសាស្ត្ររបបខ្មែរក្រហម។ ការងាររបស់យើងនឹងផ្តោតលើ ប្រជាជនកម្ពុជារួមមានជនរងគ្រោះ និងកូនចៅជំនាន់ក្រោយ ដែលជាអ្នកឆ្លុះបញ្ចាំងអំពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់ប្រទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងទាក់ទង ក៏ដូចជាគាំទ្រប្រជាជន កម្ពុជាដែលរស់នៅបែកខ្ញែកពីគ្នានៅជុំវិញពិភពលោក។ គម្រោងយុទ្ធសាស្ត្រសង្ខេបនេះបង្ហាញពីគម្រោងរបស់យើង ក្នុងការបង្កើតយន្តការដ៏ស្វិតស្វាញមួយ ដើម្បីធ្វើអប្បបរមាកម្មស្រមោលអន្ធការនៃភាពតក់ស្លុតរបស់របបខ្មែរក្រហម ធ្វើអន្តរកម្មទៅជាប្រទេសមួយដែលបម្រើនាទីជានិមិត្តរូបសកល ដែលសង្គមក្រោយជម្លោះអាចរីកលូតលាស់ និងប្រែក្លាយទៅជាសង្គមប្រជាធិបតេយ្យដ៏ជឿនលឿនមួយ។

# ១. កេរដំណែលនៃការចងចាំ

## ការស្រាវជ្រាវ និងការចងក្រងឯកសារ

ការចងក្រងឯកសារពីអំពើឃោរឃៅរបស់ខ្មែរក្រហមនឹងនៅតែជាអាទិភាពស្នូលចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងរយៈពេលបួនឆ្នាំខាងមុខ។ អ្នករស់រានមានជីវិតពីរបបនេះជាច្រើននាក់ បានទទួលអនិច្ចកម្មដោយសារជរាភាពជាបន្តបន្ទាប់ ក្នុងនោះក៏មានអ្នកដែលកំពុងបាត់បង់ការចងចាំ។ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតគឺជាមូលដ្ឋានគ្រឹះសម្រាប់ប្រវត្តិសាស្ត្ររបស់ជាតិ។ ឯកសារជាច្រើនបានបាត់បង់ និងទាមទារឲ្យមានការស្រាវជ្រាវជាច្រើន។ សំឡេងរបស់អតីតសមាជិកខ្មែរក្រហមក៏នឹងត្រូវបានឮតាមរយៈគម្រោងលើកកម្ពស់ឲ្យមានការទទួលខុសត្រូវរបស់យើង ដែលបន្តស្រាវជ្រាវដើម្បីសម្រេចបានការយល់ដឹងស៊ីជម្រៅជាងមុនអំពីរចនាសម្ព័ន្ធនៃការបញ្ជារបស់របបខ្មែរក្រហម ក្នុងអំឡុងពេលឈានទៅមុខ និងធ្លាក់ចុះ។ យើងបន្តស្រាវជ្រាវថាតើអតីតសមាជិកខ្មែរក្រហមរស់នៅក្នុងពេលបច្ចុប្បន្ន នឹងដោះស្រាយចំពោះកេរដំណែលដែលអន្តរាយរបស់ខ្លួនដោយរបៀបណា។ យើងគ្រោងធ្វើការស្រាវជ្រាវបន្ថែមទៀតអំពីអ្នករស់រានមានជីវិត ក៏ដូចជាប្រមែប្រមូលឯកសារពីបុគ្គលនីមួយៗ ស្ថាប័នឯកជន និងអតីតបណ្ណសារដ្ឋានប្រទេសកុម្មុយនីស្តនានា។

សកម្មភាពចងក្រងឯកសារ និងស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាប្រព្រឹត្តទៅរួមគ្នា។ ការពង្រីកការចងក្រង ឯកសាររបស់យើងមាននាទីជាធនធានមួយសម្រាប់ទាំងអ្នកស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ។ នៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់ យើងនឹងធ្វើការសិក្សាអំពីអតីតសមាជិកខ្មែរក្រហមថ្នាក់ក្រោម ចាប់ពីថ្នាក់ធំមកថ្នាក់តូច ព្រមទាំងរចនាសម្ព័ន្ធស្ថាប័នរបស់អ្នកទាំងនោះ។ លទ្ធផលដែលទទួលបាន នឹងពង្រឹងការយល់ដឹងរបស់យើងអំពីប្រវត្តិសាស្ត្រនៃអំឡុងពេលនោះ និងរបៀបដែលគោលនយោបាយស្តីពីអំពើឃោរឃៅទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងបណ្តាជាន់ថ្នាក់នៃរដ្ឋបាលខ្មែរក្រហម។

នៅពេលពាក់កណ្តាលឆ្នាំនៃចក្ខុវិស័យជាយុទ្ធសាស្ត្រនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងធ្វើឲ្យបណ្ណសារទាំងមូលរបស់ខ្លួនក្លាយជាទម្រង់បច្ចេកវិទ្យា ដើម្បីអាចឲ្យមានការប្រើប្រាស់បណ្ណសាររបស់ខ្លួនបានតាមប្រព័ន្ធអ៊ីនធឺណិតនៅពាសពេញពិភពលោក។ ដំបូង យើងនឹងធ្វើការថតចម្លងតាមម៉ាស៊ីនកំព្យូទ័រលើឯកសារដែលនៅសេសសល់ក្នុងបណ្ណសារដ្ឋាន ដោយផ្អែកតាមបទដ្ឋាននៃវិស័យបណ្ណសារ។ ក្រោយមកទៀត យើងនឹងជ្រើសរើសអ្នកជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មានក្នុងស្រុក និងអន្តរជាតិ ដើម្បីប្រើប្រាស់ឧបករណ៍វិភាគឯកសារដោយប្រើបច្ចេកទេសអុបទិក ឧបករណ៍ស្វែងរកដ៏មានឥទ្ធិពល និងកម្មវិធីវិភាគសំឡេង។

## ការអប់រំពីអំពើប្រល័យពូជសាសន៍

## ការអប់រំពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមក្នុងប្រទេសកម្ពុជា

ការអប់រំពីអំពើប្រល័យពូជសាសន៍មានសារៈសំខាន់ណាស់ ក្នុងការថែរក្សាការចងចាំរបស់ប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតក្នុងអំពើព្រៃផ្សៃរបស់ខ្មែរក្រហម ជាពិសេសក្នុងជម្រៅចិត្ត និងសម្បជញ្ញៈរបស់មនុស្សជំនាន់ក្រោយដែលជាប្រជាជនវ័យក្មេង។ ការអប់រំប្រភេទនេះចាំបាច់ណាស់ប្រសិនបើប្រជាជនកម្ពុជាមានបំណងចង់ដឹងអំពីមូលហេតុ និងរបៀបដែលអំពើប្រល័យពូជសាសន៍បានកើតឡើង យល់ដឹងអំពីផលប៉ះពាល់នៃសោកនាដកម្មនេះ និងដោះស្រាយឧបសគ្គបន្តបន្ទាប់ជាច្រើនដែលកើតមានដោយសារអំពើប្រល័យពូជសាសន៍។



កសិករម្នាក់ដែលកំពុងច្រូតស្បូវនៅខេត្តកំពង់ធំ គឺជាអ្នករស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នករស់រានមានជីវិតរាប់លាននាក់ទៀត ដែលរស់រានមានជីវិតពីអំពើឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ស្ថិតនៅក្រោមរបបនេះ ប្រជាជនប្រមាណពីរលាននាក់បានបាត់បង់ជីវិតដោយសារតែការបង្អត់អាហារ ការធ្វើការងារហួសកម្លាំង ទារុណកម្ម និងការសម្លាប់។ អ្នករស់រានមានជីវិតពីអំពើឃោរឃៅនេះ នៅតែបន្តរងទុក្ខពីឥទ្ធិពលអូសបន្លាយនៃការប៉ះទង្គិចផ្លូវអារម្មណ៍ ដែលបង្កទៅជាជំងឺរ៉ាំរ៉ៃទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ អ៊ូច មករា។ ការពិពណ៌នា៖ ស៊ីវិ សាវីណា*

ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានអប់រំនានា មជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតបាននូវកម្មវិធីសិក្សាគោលមួយស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំប្រឆាំងនឹងមនុស្សជាតិ។ កម្មវិធីនេះត្រូវបានដាក់បញ្ចូលក្នុងថ្នាក់រៀនរបស់កម្ពុជាក៏ដូចជាសហគមន៍អប់រំជាន់ខ្ពស់ ព្រមទាំងការអប់រំបន្តសម្រាប់ជំនាញវិជ្ជាជីវៈដូចជាយោធា ប៉ូលីស និងគ្រូបង្រៀនដែលផ្តល់សេវាកម្មសិក្សា។ រួមគ្នាជាមួយនឹងអ្នកជំនាញទាំងក្នុងស្រុក និងអន្តរជាតិ យើងបានផ្តល់នូវការបណ្តុះបណ្តាលស៊ីជម្រៅទៅកាន់មន្ត្រីរាជការ និងគ្រូបង្រៀនកម្ពុជារាប់ពាន់នាក់នៅគ្រប់បណ្តាខេត្តក្នុងប្រទេសកម្ពុជា។ យ៉ាងណាក្តី ការងាររបស់យើងនៅមិនទាន់ពេញលេញនៅឡើយទេ ហើយបញ្ហាប្រឈមក៏នៅមានកម្រិតខ្ពស់។

កម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាលរបស់យើង ប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្ររៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា៖ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" និងសៀវភៅជំនួយរបស់យើង គឺសៀវភៅណែនាំគ្រូបង្រៀន។ សៀវភៅនេះបានទទួលការកោតសរសើរពីជុំវិញប្រទេស និងពិភពលោក។ សៀវភៅនេះជាសៀវភៅដំបូងគេបំផុតក្នុងចំណោមសៀវភៅប្រវត្តិសាស្ត្រ។ បន្ទាប់ពីមិនធ្លាប់មានការលើកឡើងអំពីប្រវត្តិសាស្ត្រនេះតាមបណ្តាសាលារៀនរបស់កម្ពុជាជាងបីទសវត្សរ៍មក មជ្ឈមណ្ឌលឯកសារកម្ពុជា រួមសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា បានអប់រំយុវជនកម្ពុជានៅក្នុងបណ្តាខេត្ត និងស្រុកទាំងអស់ ក្នុងប្រទេសកម្ពុជា។ កម្មវិធីសិក្សា

របស់យើងទទួលបានការលើកទឹកចិត្តចំពោះសំណេរអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលសេរី ប៉ុន្តែត្រឹមត្រូវ ដោយធ្វើឲ្យមានសមតុល្យរវាងការលើកឡើងអំពីឧក្រិដ្ឋកម្មដ៏ឃោរឃៅ រួមជាមួយនឹងការគោរពដ៏មុតមាំចំពោះសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះជាទូទៅ។ រក្សានូវតុល្យភាពរវាងការពិត និងចំណុចរសើប គឺជាកត្តាចំបាច់បំផុត របស់កម្មវិធីអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមិនត្រឹមតែមានគោលបំណងអប់រំតែប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបុព្វហេតុនៃការចងចាំថែមទៀតផង។ ការអប់រំពីអំពើប្រល័យពូជសាសន៍ដ៏មានប្រសិទ្ធភាព គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ការបង្កើនថាមពល សង្គម។ កម្មវិធីនេះប៉ុនប៉ងរំដោះអ្នករស់រានមានជីវិតឲ្យចេញពីភាពភ័យខ្លាចចំពោះរបបខ្មែរក្រហម និងធ្វើឲ្យអ្នកទាំងនេះទៅជាអ្នកដឹកនាំក្នុងបុព្វហេតុសកលសម្រាប់សិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូរ។

កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងមិនស្ថិតតែនៅក្នុងដែនកំណត់របស់កម្ពុជាទេ។ យើងក៏ប្រមើលមើលនូវកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ដ៏ស្វាហាប់មួយ សម្រាប់ប្រទេសទាំងអស់ដែលស្ថិតក្នុងតំបន់ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។

## ការអប់រំពីសន្តិភាព និងសិទ្ធិមនុស្ស

ម ជ្ឈ មណ្ឌលឯកសារកម្ពុជាប្រមើលមើលកម្មវិធីសិក្សាអំពីសន្តិភាពមួយដែលបំពេញបន្ថែមដល់សេចក្ដីថ្លែងកា រណ៍របស់អាស៊ានស្ដីពីចលនាសកលនៃភាពអព្យាក្រឹត្យ និងសន្ធិសញ្ញាដទៃទៀតដែលត្រូវបានទទួលស្គាល់ជាសកលដូចជា អនុសញ្ញាស្ដីពីការបង្ការនិងការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិមនុស្សក្នុងសហគមន៍អាស៊ាន។ កម្មវិធីនេះនឹងបញ្ជាក់អំពីការប្ដេជ្ញាចិត្តរបស់ប្រទេសជាសមាជិកចំពោះសិទ្ធិមនុស្ស និងសម្រេចបានការទទួលស្គាល់ពីប្រជាជនងាយរងគ្រោះបំផុត ពោលគឺយុវជនរបស់យើង។

បទពិសោធន៍របស់កម្ពុជាចំពោះអំពើប្រល័យពូជសាសន៍ក៏នឹងមានតួនាទីជាសំអាងដ៏សំខាន់ចំពោះកម្មវិធីសិក្សានេះ។ មជ្ឈមណ្ឌលឯកសារកម្ពុជារំពឹងនូវតួនាទីសម្របសម្រួលចម្បងមួយ នៅក្នុងកម្មវិធីសិក្សាអំពីសន្តិភាព និងសិទ្ធិមនុស្សសម្រាប់តំបន់អាស៊ាន តាមរយៈការរៀបចំ ការសម្របសម្រួល និងការផ្ដល់នូវជំនាញបច្ចេកទេស។

ប្រសិនបើត្រូវបានបង្កើតឡើង កម្មវិធីសិក្សានេះនឹងប្រកបដោយភាពបង្កើតថ្មី និងនិរន្តរភាព។ វានឹងដើរតួនាទីជាគំរូមួយសម្រាប់ប្រទេស និងតំបន់ដទៃទៀត ក្នុងការឆ្លើយតប និងរារាំងចំពោះភេរវកម្ម អំពើឃោរឃៅទ្រង់ទ្រាយធំ ព្រមទាំងអំពើហិង្សា និងគំនិតជ្រុលនិយម។

## មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងត្រូវបានបង្កើតឡើងជាផ្លូវការនៅក្នុងឆ្នាំ២០១៥ ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួងទេសចរណ៍ ដោយធ្វើការផ្ដល់នូវកម្មវិធីសិក្សាអប់រំ និងផ្សះផ្សាថ្នាក់សហគមន៍ផ្ដោតលើការផ្សារភ្ជាប់ភាពបែងចែក និងការផ្ដាច់ខ្លួនរវាងអតីតសមាជិកខ្មែរក្រហម នៅក្នុងតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម (ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ) និងយុវជនកម្ពុជាជំនាន់ក្រោយ។ កម្មវិធីសិក្សានេះក៏ផ្ដល់នូវបែបផែនអប់រំសម្រាប់ការសម្រាលនូវជម្លោះមនុស្ស និងការជំរុញឲ្យមានការចូលរួមបែបស៊ីវិលឲ្យកាន់តែប្រសើរជាងមុន។

គម្រោងនេះនឹងនាំយកសិស្សានុសិស្សសាកលវិទ្យាល័យ ទៅកាន់តំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហមនៅអន្លង់វែង តាមរយៈទស្សនកិច្ចសិក្សាចំនួន៤ថ្ងៃ ដោយរួមបញ្ចូលនូវសកម្មភាពអប់រំប្រចាំថ្ងៃដែលទាមទារឲ្យមានការត្រិះរិះពិចារណា ការឆ្លុះបញ្ចាំង និងការតស៊ូមតិ ព្រមទាំងឱកាសក្នុងការធ្វើអន្តរ កម្ម និងចោទសួរទៅកាន់អតីតសមាជិកខ្មែរក្រហម និងជនរងគ្រោះដែលរស់នៅក្នុងតំបន់អន្លង់វែង។ កម្មវិធីសិក្សានេះលើកកម្ពស់ការយល់ដឹងប្រកបដោយការត្រិះរិះពិចារណាអំពីប្រវត្តិសាស្ត្រហិង្សារបស់កម្ពុជានៅក្នុងបរិបទនៃទ្រឹស្ដីប្រកួតប្រជែងក្នុងការដោះស្រាយ និងការបម្លែងជម្លោះ។ ដំណើរទ ស្ស នកិច្ចនេះសម្រេចកម្មវត្ថុរបស់ខ្លួនតាមរយៈកិច្ចពិភាក្សាអន្តរកម្ម ការធ្វើមគ្គុទេសក៍ទស្សនកិច្ចទៅកាន់ទីតាំងប្រវត្តិសាស្ត្រខ្មែរក្រហមទាំង១៤ក្នុងតំបន់ និងកម្មវិធីសិក្សាដែលប្រើប្រាស់រឿងរ៉ាវជីវិតរបស់បុគ្គលដើម្បីបង្ហាញអំពីមេរៀនប្រវត្តិសាស្ត្រ និងសីលធម៌។

បន្ថែមលើការផ្ដល់ជូនដំណើរទស្សនកិច្ចនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគាំទ្រដល់ការសិក្សាស្រាវជ្រាវ និងការយល់ដឹងថ្នាក់ជាតិ អំពីប្រវត្តិសាស្ត្រនៃចលនារបស់ខ្មែរក្រហម តាមរយៈឯកសារបោះពុម្ព បណ្ណាល័យ និងការងារចងក្រងឯកសារជាបន្តបន្ទាប់។ បេសកកម្មរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺមិនត្រឹមតែពង្រីកឥទ្ធិពលនៃកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ ដែលត្រូវបានអនុវត្តនៅតាមបណ្ដាសាលារៀនក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកវិសាលភាពនៃចំណេះដឹងសាធារណៈអំពីប្រវត្តិសាស្ត្រនៃចលនារបស់ខ្មែរក្រហមដែលមិនស្ថិតនៅក្នុងទំហំនៃការវិនិច្ឆ័យរបស់តុលាការខ្មែរក្រហម។ ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្ដោបលើអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចលនារបស់ខ្មែរក្រហមនៅមុនពេលរបបនេះកាន់អំណាច និងការដួលរលំនៃរបបនេះ។

លទ្ធិប្រជាធិបតេយ្យមិនសុទ្ធតែកើតចេញមកពីសាលាក្រុង អគារសភា និងកែងផ្លូវនោះទេ។ លទ្ធិប្រជាធិបតេយ្យក៏អាចចាប់ផ្ដើមចេញពីថ្នាក់រៀនដែរ។ ការអប់រំ ជាពិសេសតាមបែបសិស្សមជ្ឈិម ក្ដោបនូវសំពាធរួមមួយរវាងតម្រូវការក្នុងការផ្លាស់ប្ដូរ និងតម្រូវការក្នុងការទទួលបានស្ថិរភាព។ សំពាធនេះបង្កើតឲ្យមានការពិភាក្សាដែលសង្គមក្រោយជម្លោះត្រូវតែប្រកាន់ខ្ជាប់ ប្រសិនបើសង្គមនេះចង់ដកខ្លួនចេញពីរង្វិលជុំប្រវត្តិសាស្ត្រនៃភាពចង្អៀតចង្អល់ ការគាបសង្កត់ និងអំពើហិង្សា។ ក្នុងន័យនេះ ការអប់រំជាផ្លូវមួយសម្រាប់សេរីភាពដ៏ថ្មីសន្លាង។រូបភាពនេះបង្ហាញអំពីសិស្សានុសិស្សថ្នាក់ទី១២មួយក្រុម មកពីវិទ្យាល័យអរុណវត្តី ជាវិទ្យាល័យមួយក្នុងចំណោមវិទ្យាល័យ១៥នៃវិទ្យាល័យទាំងអស់នៅក្នុងរាជធានីភ្នំពេញ ដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើវេទិការថ្នាក់រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សិស្សទាំងនេះកំពុងរង់ចាំត្រង់ត្រាប់ទទួលយកការបង្ហាត់បង្ហាញ ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទទួលយកសៀវភៅសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សៀវភៅសិក្សានេះត្រូវបានប្រគល់ជូនសិស្សម្នាក់ៗ ក្នុងអំឡុងពេលវេទិកាថ្នាក់រៀនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ អ៊ូច មករា។ ការពិពណ៌នា៖ ផេង ពង្សរ៉ាស៊ី*



ការតំណាងនៃអតីតកាលត្រួសត្រាយអំពីបច្ចុប្បន្នកាល និងអនាគតកាល។ ការចងចាំធ្វើឲ្យអតីតកាលក្លាយជាចលករជំរុញសកម្មក្នុងជីវិតរបស់យើង ដោយរំលេចឲ្យឃើញថា យើងជានរណា ទីណាដែលយើងគួរទៅ និងជាចុងក្រោយ អ្វីដែលយើងនឹងក្លាយខ្លួនទៅជា។ ប្រាសាទអង្គរវត្ត ត្រូវបានកសាងឡើងនៅដើមសតវត្សរ៍ទី១២ ដោយស្ដេចខ្មែរមួយអង្គ ព្រះនាមសូរ្យវរ្ម័នទី២។ ប្រាសាទនេះជាវិមានសាសនាធំជាងគេលើពិភពលោក។ ប្រាសាទនេះមិនត្រឹមតែតំណាងឲ្យអតីតកាលរបស់កម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការអះអាងមួយអំពីអត្តសញ្ញាណ ការតស៊ូ និងចក្ខុវិស័យជានិរន្តរ៍របស់កម្ពុជាដើម្បីអនាគតថែមទៀតផង។

*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ ម៉េង គីមឡុង។ ការពិពណ៌នា៖ ចាន ប្រាថ្នា*



# ២. កេរដំណែលនៃការសះស្បើយ

## សៀវភៅចងចាំរបស់មនុស្សជាតិ

*សៀវភៅចងចាំរបស់មនុស្សជាតិ* គឺជាធាតុផ្សំដទៃទៀតនៃសកម្មភាពចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ សៀវភៅនេះគឺជាគម្រោងដែលពោរពេញដោយមហិច្ឆិតាក្នុងការប្រមែប្រមូលឈ្មោះ និងសាវតាររបស់អ្នកដែលបាត់បង់ជីវិត ឬបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម។ រូបថត និងវត្ថុដទៃទៀត ដែលបញ្ជាក់អំពីបុគ្គលទាំងនេះនឹងត្រូវបានប្រមូល និងប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណ។

គម្រោងសៀវភៅចងចាំរបស់មនុស្សជាតិមានបំណងផ្តល់នូវការយល់ដឹង ដែលស៊ីជម្រៅជាងមុនទាក់ទងនឹងការស្លាប់ ដែលកើតមានឡើងក្នុងអំឡុងរបបខ្មែរក្រហម ដោយភ្ជាប់ស្ថិតិទៅនឹងរឿងជីវិតបុគ្គល។ គម្រោងនេះនឹងបំពេញបន្ថែមលើគម្រោងផែនទីវាលពិឃាតនៅក្នុងឆ្នាំ២០០៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ដែលបញ្ជាក់អំពីទីតាំងរណ្តៅសាកសពរួមទាំងអស់) ដោយប្រមូលផ្តុំប្រវត្តិសាស្ត្រគ្រប់ជ្រុងជ្រោយពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមតាមរយៈរឿងរ៉ាវផ្ទាល់ខ្លួនរបស់បុគ្គល។ ជាចុងក្រោយ គម្រោងនេះនឹងរៀបចំ ក៏ដូចជាវិភាគអំពីលំនាំនៃការស្លាប់ក្នុងរបបខ្មែរក្រហមដែលរួមមាន ទីតាំង សភាពនៃការស្លាប់ ឧបករណ៍ដែលបានប្រើប្រាស់ អាយុជាមធ្យម ភេទ និងការស្លាប់ដែលរាលដាល នៅអំឡុងពេលប៉ុន្មានឆ្នាំដែលស្ថិតក្រោមរបបខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានឈ្មោះរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបាត់បង់ជីវិតចំនួនប្រមាណមួ យលាននាក់ នៅក្នុងប្រព័ន្ធទិន្នន័យរបស់ខ្លួន។ ជំហានបន្ទាប់នៃគម្រោងនេះគឺធ្វើការកត់ត្រាឈ្មោះរបស់អ្នកដែ លរស់រានមានជីវិត។ អ្នកទាំងនេះជាប្រភពផ្តល់ព័ត៌មានផ្ទាល់អំពីសាច់ញាតិ ដែលបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ គម្រោងនេះនឹងត្រូវបញ្ចប់ បន្ទាប់ពីឈ្មោះចំនួនជាង ពីរលានត្រូវបានបញ្ចូលនៅក្នុងទិន្នន័យ។

## ការចុះទៅកាន់ភូមិអ្នកស្រុក និងកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ការអប់រំពីអំពើប្រល័យពូជសាសន៍ ការធ្វើឲ្យសះស្បើយ និងការផ្សះផ្សា

មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយនឹងស្ថាប័នអន្តរជាតិជាច្រើន រាប់ចាប់ពីសារមន្ទីរ និងបណ្ណសារដ្ឋាន រហូតដល់ស្ថាប័នសិទ្ធិមនុស្ស អ្នកផលិតខ្សែភាពយន្ត និងអង្គភាពអាជីវកម្ម។ មជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋាភិបាល និងស្ថាប័នសង្គមស៊ីវិលថាជាមធ្យោបាយមួយដែលមិនត្រឹមតែអាចបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលរបស់ខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែជាការធ្វើឲ្យប្រសើរឡើងនៃសង្គមស៊ីវិលថែមទៀត។

មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងបុគ្គល រាជរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងទំហំមួយយ៉ាងទូលាយ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើសហប្រតិបត្តិការជាមួយសារម ន្ទីរនានា ដូចជាសារមន្ទីរហូឡូខស្ទ សហរដ្ឋអាមេរិក និងអង្គការសារមន្ទីរសម្បជញ្ញៈសកលលោក។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានស ម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងចងក្រងឯកសារនៃប្រ ទេ សដទៃទៀតចាប់ពីស្ថាប័នសិទ្ធិមនុស្សក្នុងប្រទេសមីយ៉ាន់ម៉ា/ភូមា និងប្រទេសថៃ រហូតដល់ ស្ថាប័នដែលទាក់ទងនឹងយុត្តិធម៌អន្តរកាល និងការអប់រំ ក្នុងប្រទេសស៊ីរី អ៊ីរ៉ាក់ កូឡុំប៊ី និងកូរ៉េខាងត្បូង។ មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយ និងទទួលបានការគាំទ្រពីបណ្តាញទាក់ទងសកលនៃស្ថាប័ននានា ដែលបូជាដើម្បីយុត្តិធម៌ សិទ្ធិមនុស្ស និងភាពប្រសើរឡើងនៃសង្គមប្រជាធិបតេយ្យផ្អែកលើនីតិរដ្ឋ។



និស្សិតស្ម័គ្រចិត្តមួយក្រុមមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលជាគម្រោងមួយផ្តួចផ្តើមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ គោលបំណងនៃគម្រោងនេះគឺដើម្បីអភិរក្ស និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រទាំង១៤កន្លែងនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលត្រូវបានស្គាល់ថាជាតំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម។ សន រឿង អតីតអង្គរក្សរបស់ តាម៉ុក ដែលជាមេបញ្ជាការកងទ័ពខ្មែរក្រហម បានរំឭកអំពីការចងចាំរបស់គាត់ទាក់ទងនឹងអតីតវាលស្រែគំរូប្រាប់ទៅកាន់ក្រុមនិស្សិត។ ការបំពេញការងារស្ម័គ្រចិត្តរបស់និស្សិត បានជួយដល់ការចាប់ផ្តើមនៃកម្មវិធីទស្សនកិច្ចសិក្សាសន្តិភាព នៅស្រុកអន្លង់វែង ជាគម្រោងអប់រំដែលមាននិស្សិតចូលរួមជាដំបូងមានចំនួន១៥នាក់។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/អ៊ួច មករា។ ការពិពណ៌នា៖ បណ្ឌិត លី សុខឃាង*

មជ្ឈមណ្ឌលឯកសារកម្ពុជាបន្តចងក្រងរឿងរ៉ាវរបស់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ តាមរយៈបណ្ណសារសោតទស្សន៍នៃប្រវត្តិសាស្ត្រខ្មែរក្រហមដែលត្រូវបាននិយាយដោយផ្ទាល់មាត់។ តាមរយៈធនធាននេះ មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងបញ្ជាក់ឲ្យឃើញអំពីជនរងគ្រោះនៃអំពើប្រល័យពូជសាស ន៍ ដែលមានបទពិសោធន៍ផ្សេងពីគ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីដោះដូរអំពីការយល់ឃើញ និងបទពិសោធន៍ជាមួយនឹងបុគ្គលដែលមាននាទីជាកម្មាភិបាលខ្មែរក្រហមក្នុងតំបន់នៅក្នុងអំឡុងរបបតែមួយ។ ការប្រមូលចងក្រងនេះនឹងផ្តុំនូវទិន្នន័យពីគម្រោងលើកកម្ពស់តម្លាភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងការស្រាវជ្រាវបែបប្រវត្តិសាស្ត្រផ្ទាល់មាត់ជាច្រើនអនេក រួមមាន បណ្ណសារភាពយន្ត ដែលថែរក្សាទុកសម្រាប់ការសិក្សាធ្វើឡើងដោយសិស្ស និស្សិត បញ្ញវន្ត និងសាធារណជន។

## វិទ្យាស្ថានស្លឹករឹត៖
## ការសាងសង់នូវមជ្ឈមណ្ឌលស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍អចិន្ត្រៃយ៍មួយ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមធ្វើការជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយ ដើម្បីពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន និងធានានូវការប្តេជ្ញារយៈពេលវែងចំពោះសិទ្ធិមនុស្ស និងការរារាំងអំពើប្រល័យពូជសាសន៍ក្នុងប្រទេស

កម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ដីមួយកន្លែងនៅក្នុងរាជធានីភ្នំពេញដើម្បីបម្រើដល់គោលបំណងនេះ។ ដីដែលមានទំហំសរុបប្រមាណ ៤៨០០ម៉ែត្រការ៉េនេះ ស្ថិតនៅក្នុងបរិវេណនៃវិទ្យាល័យបឹងត្របែក ដែលជាទីតាំងនៃអតីតមន្ទីរអប់រំកែប្រែមួយរបស់ខ្មែរក្រហម។ យើងបានជ្រើសរើសក្រុមស្ថាបត្យករជំនាញមួយក្រុមនៅទីក្រុងឡុងដ៍ឲ្យធ្វើការរចនាបណ្តុំអាគារ ដែលជាទីតាំងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍។ យើងកំពុងធ្វើការជាមួយនឹងរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់យកកាលបរិច្ឆេទមួយសម្រាប់រៀបចំពិធីបញ្ចុះបឋមសិលានៅទីតាំងនៃបណ្តុំអគារថ្មីមួយនេះ ដែលមានឈ្មោះថា "វិទ្យាស្ថានស្លឹករឹត"។ វិទ្យាស្ថានស្លឹករឹតរួមបញ្ចូលនូវ ១)សារមន្ទីរនៃការចងចាំ ២)គ្រឹះស្ថានសិក្សាពីអំពើប្រល័យពូជសាសន៍និងសិទ្ធិមនុស្ស ៣)មជ្ឈមណ្ឌលស្រាវជ្រាវ ៤)បណ្ណាល័យ និង ៥)បណ្ណសារដ្ឋានឯកសារនៃរបបខ្មែរក្រហម ព្រមទាំងអគាររដ្ឋបាល និងវិចិត្រសាលសិល្បៈសហសម័យ។ បុគ្គលិកវិទ្យាស្ថានស្លឹករឹតនឹងរៀបចំ ក៏ដូចជា អនុវត្តកម្មវិធីសិក្សាផ្សេងៗទាក់ទងនឹងបេសកកម្មទាំងមូលរបស់វិទ្យាស្ថាន ក្នុងការលើកកម្ពស់ការអប់រំក្នុងស្រុក និងក្នុងតំបន់ ព្រមទាំងការយល់ដឹង ក្នុងគោលបំណងធានាដល់ការថែរក្សាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មឃោរឃៅ។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រវិទ្យាស្ថានស្លឹករឹតជាសាធារណៈ ព្រមទាំងបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ស្តីពីការផ្តល់ដីមួយកន្លែងក្នុងរាជធានីភ្នំពេញ ដូចដែលបានរៀបរាប់ខាងលើ។ លក្ខខណ្ឌនៃអនុស្សារណៈយោគយល់គ្នានោះគឺ ធ្វើការផ្តល់សិទ្ធិទាំងអស់ក្នុងការប្រើប្រាស់ដីចំនួន៦ហិកតានេះ ក្នុងរយៈពេល៩០ឆ្នាំ។ ក្រសួងអប់រំបានចាត់ទុកវិទ្យាស្ថានស្លឹករឹតជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើឲ្យមានការចូលរួមពីសំណាក់ក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីត ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ដើម្បីរចនាវិទ្យាស្ថានស្លឹករឹត។ នៅត្រឹមខែកុម្ភៈ ឆ្នាំ២០១៥ ក្រុមហ៊ុនស្ថាបត្យកម្ម ហ្សាហា ហាឌីត បានបញ្ចប់ការរចនាអគារ និងបំពេញការងាររចនាលម្អិតសម្រាប់អគារនេះ។ ចាប់តាំងពីពេលនោះមកដំណើរការផ្សេងទៀតត្រូវបានពន្យារដោយសារតែសកម្មភាពរៃអង្គាសថវិកាសម្រាប់ការសាងសង់កំពុងបន្តទៅមុខ។ ដំណើរការនៃវិទ្យាស្ថានត្រូវបានសង្ខេបខាងក្រោមនេះ។

ឈ្មោះ "វិទ្យាស្ថានស្លឹករឹត" ឆ្លុះបញ្ចាំងអំពីគោលបំណងស្នូលរបស់យើង ក៏ដូចជាបេតិកភណ្ឌរបស់ប្រជាជនកម្ពុជាដែរ។ ស្លឹករឹត គឺជាស្លឹករុក្ខជាតិស្ងួតដែលមេដឹកនាំសាសនា និងបញ្ញវន្តខ្មែរប្រើប្រាស់ជាច្រើនសតវត្សរ៍ដើម្បីកត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ផ្សព្វផ្សាយចំណេះដឹង និងថែរក្សាវប្បធម៌ក្នុងយុគសម័យរីករវរ។ ស្លឹកនេះតំណាងឲ្យទាំងសោភ័ណភាពនៃចំណេះដឹងក៏ដូចជាអំណាចក្នុងការថែរក្សារបស់មនុស្សក្នុងអំឡុងពេលមានហានិភ័យ។ មជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍មួយនេះ នឹងបម្រើតួនាទីចម្បងបី។ ទីមួយគឺ វិទ្យាស្ថាននេះ គឺជាការចងចាំលក្ខណៈរូបដែលជំរុញឲ្យអ្នកទស្សនាផ្តល់កិត្តិយស និងចងចាំដល់ជនរងគ្រោះរាប់លាននាក់ដែលលាចាកលោកនេះទៅ និងអ្នកទាំងអស់ដែលរងទុក្ខក្រោមរបបខ្មែរក្រហម។ ទីពីរ វិទ្យាស្ថាននេះ គឺជាទីតាំងអប់រំ ដែលអាចឲ្យមនុស្សជំនាន់បច្ចុប្បន្ន និងអនាគត សិក្សាអំពីប្រវត្តិសាស្ត្រដ៏គួរឲ្យរន្ធត់របស់កម្ពុជា។ ការអប់រំនឹងធានាថាប្រជាជនកម្ពុជានឹងមិនបំភ្លេចអ្នកដែលបានបាត់បង់ជីវិត និងរងទុក្ខ ព្រមទាំងផ្តល់ថាមពលដល់មនុស្សជំនាន់បច្ចុប្បន្នឲ្យយល់ដឹង និងស្វែងរកមធ្យោបាយរារាំងការបំពាន ដែលស្រដៀងនឹងនេះនាពេលអនាគត។ ចុងក្រោយ វិទ្យាស្ថាននេះគឺជាមជ្ឈមណ្ឌលស្រាវជ្រាវ ដែលស្វះស្វែងបម្លែងខ្លួនឲ្យទៅជាវិទ្យាស្ថានក្នុងតំបន់អាស៊ីដែលឈានមុខដោយផ្តោតលើការសិក្សាពីអំពើប្រល័យពូជសាសន៍ អមជាមួយនឹងបណ្តាញនានា ដើម្បីដឹកនាំសិស្ស និស្សិត បញ្ញវន្ត និងស្ថាប័នដទៃក្នុងទ្វីបអាស៊ី និងក្នុងពិភពលោក។

# ៣. កេរដំណែលយុត្តិធម៌

## សិក្សាស្រាវជ្រាវលើឧក្រិដ្ឋកម្មបង្កឡើងដោយថ្នាក់ក្រោម

មជ្ឈមណ្ឌលឯកសារកម្ពុជាស្វះស្វែងពង្រីកកេរដំណែលយុត្តិធម៌ ដែលកំពុងធ្វើឡើងនៅតុលាការខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រោងនឹងធ្វើការសិក្សាស្រាវជ្រាវមួយ ស្វែងរកការបំពានរបស់ខ្មែរក្រហមជាច្រើនដែលស្ថិតក្រៅតំបន់នៃការស្រាវជ្រាវពីឧក្រិដ្ឋកម្មបង្កឡើងដោយសមាជិកខ្មែរក្រហមថ្នាក់ក្រោម។ ចាប់តាំងពីឆ្នាំ២០០១មក ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើបទសម្ភាសរាប់ពាន់ជាមួយនឹងអតីតសមាជិក និងកម្មាភិបាលខ្មែរក្រហម។ ការសិក្សានេះនឹងផ្តល់ជូនជនរងគ្រោះ ពោលគឺអ្នកដែលមានអារម្មណ៍ថាត្រូវបានកាត់ផ្តាច់ពីដំណើរការច្បាប់ប្រព្រឹត្តទៅនៅតុលាការខ្មែរក្រហម នូវឱកាសមួយក្នុងការរៀបរាប់អំពីបទពិសោធន៍របស់ខ្លួន ដើម្បីឲ្យជនរងគ្រោះទាំងនេះអាចទទួលយកនូវអតីតកាលរបស់ខ្លួន។ ដូចគ្នាទៅនឹងគណៈកម្មាធិការស្វែងរកការពិត និងការផ្សះផ្សានៅអាហ្វ្រិកខាងត្បូងដែរ ការសិក្សានេះមិនមែនធ្វើឡើងដើម្បីដាក់ការស្តីបន្ទោសលើបុគ្គលជាក់លាក់ណាមួយនោះទេ ផ្ទុយទៅវិញគឺដើម្បីឲ្យជនរងគ្រោះ និងអ្នកប្រព្រឹត្តខុសទទួលបានឱកាសក្នុងការនិយាយ និងធ្វើឲ្យរឿងរ៉ាវរបស់គាត់ត្រូវបានដឹងឮដោយអ្នកដទៃ។ នេះគឺជាជំហានដ៏ចាំបាច់មួយ ឆ្ពោះទៅរកការផ្សះផ្សាជាតិ និងយុត្តិធម៌។

## ធ្វើឲ្យសិទ្ធិមនុស្សមានភាពប្រសើរឡើង

មជ្ឈមណ្ឌលឯកសារកម្ពុជានឹងស្វះស្វែងរកការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំវេទិកាមួយរំឭកអំពីច្បាប់ស្តីពីសិទ្ធិមនុស្សសំខាន់ៗ។ ជាពិសេស យើងមានបំណងរំលេចឡើងអំពីអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាអនុសញ្ញាដ៏ចាំបាច់មួយដែលផ្តន្ទានិងរារាំងអំពើប្រល័យពូជសាសន៍ក្នុងរយៈពេលជាង៦០ឆ្នាំកន្លងមកហើយ។ យើងក៏ប៉ុនប៉ងទាញយកចំណាប់អារម្មណ៍ចំពោះសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សរបស់សហគមន៍អាស៊ានដែលធ្វើឡើងនាពេលថ្មីៗនេះដែរ។ យើងមានការរំពឹងចំពោះការដឹកនាំវេទិកាមួយដែលមានកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាភាគីដែលបានអនុវត្តអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងឆ្នាំ១៩៥០ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធមនុស្សរបស់សហគមន៍អាស៊ាន នៅខែវិច្ឆិកា ឆ្នាំ២០១២។ អនុសញ្ញាដែលលើកឡើងដំបូង តំណាងឲ្យមូលដ្ឋានគ្រឹះមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិបែបទំនើប។ ចំណែកឯសេចក្តីថ្លែងការណ៍ខាងលើវិញ បង្ហាញអំពីការប្តេជ្ញាថ្នាក់តំបន់បន្តទៀតចំពោះសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋាន។

### សេវាកម្មផ្នែកច្បាប់និងសុខាភិបាលសម្រាប់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ទាំង១៧៥០នាក់

មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកជំនួយសម្រាប់គម្រោងរបស់ខ្លួន ក្នុងការបង្កើតនូវមន្ទីរពិគ្រោះផ្នែកច្បាប់និងការថែទាំសុខភាពបណ្តោះអាសន្នមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរបស់តុលាការខ្មែរក្រហម។

មន្ទីរជំនួយផ្នែកច្បាប់ មានសារៈសំខាន់ចំពោះការគាំពារ និងធ្វើឲ្យប្រសើរឡើងនូវឥទ្ធិពលរបស់តុលាការខ្មែរក្រហម លើនីតិរដ្ឋក្នុងប្រទេសកម្ពុជា។ ប្រសិនបើត្រូវបានបង្កើតឡើង មន្ទីរពិគ្រោះនេះនឹងផ្តល់ជាជំនួយផ្នែកច្បាប់ជាមូលដ្ឋាន រាប់ចាប់ពីការប្រឹក្សាយោបល់ផ្នែកច្បាប់ជំនាញ រហូតដល់ការការពារក្តី។ មន្ទីរពិគ្រោះនេះនឹងផ្តល់នូវសេវាកម្មតំណាងនៅក្នុងកម្រិតជាក់លាក់មួយនៅតុលាការក្នុងស្រុក ក៏ដូចជាការគាំទ្រការស្រាវជ្រាវអំពី



ប្រមាណចិតសិបភាគរយនៃអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមគឺជាស្ត្រី។ភាគច្រើននៃអ្នកទាំងនេះគឺជាស្ត្រីមេម៉ាយ។ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩មក ស្ត្រីគឺជាកម្លាំងចលករដ៏ចម្បងក្នុងការកសាងជាតិឡើងវិញ។ ស្ត្រីបានពង្រឹងសេដ្ឋកិច្ចជាតិក្នុងអំឡុងពេលចលាចល ពោលគឺក្នុងអំឡុងទសវត្សរ៍ទី៨០ និង៩០ ខណៈដែលសង្គ្រាមស៊ីវិលជាមួយខ្មែរក្រហមបានកើតមាន ព្រមទាំងទណ្ឌភាពសេដ្ឋកិច្ចបានរារាំងដល់ឱកាសក្នុងការអភិវឌ្ឍ។ លើសពីនេះទៅទៀត ដោយសារតែការតស៊ូឥតងាករេនៃស្ត្រីទាំងនេះហើយ ទើបវប្បធម៌ ការអប់រំ និងប្រពៃណីរបស់កម្ពុជា ដែលស្ទើរតែបាត់បង់នៅក្នុងដៃខ្មែរក្រហម អាចឈរជើងបានសារជាថ្មីនៅក្នុងសរសៃឈាមនៃសង្គមរស់នៅប្រចាំថ្ងៃរហូតមកទល់សព្វថ្ងៃនេះ។ ស្ថិតក្នុងកាលៈទេសៈដ៏លំបាកលំបិននេះ ស្ត្រីកម្ពុជាបានបង្ហាញឲ្យឃើញនូវកម្លាំងដ៏មោះមុត និងភាពមិនទ្រុឌទ្រោម។

*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ អ៊ូច មករា។ ការពិពណ៌នា៖ ផាំង យុ*

ប្រវត្តិសាស្ត្រលក្ខណៈគ្រួសារ។មន្ទីរពិគ្រោះនេះនឹងបម្រើការដោយក្រុមមេធាវីជនជាតិកម្ពុជានៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក វ៉ាន់ថាន់ ពៅដារ៉ា ដែលជាមេធាវីជនជាតិកម្ពុជាមួយរូប ទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកច្បាប់ពីសាកលវិទ្យាល័យ ណូតគ្រី ដេម ដែលជាសាកលវិទ្យាល័យកាតូលិកដ៏លេចធ្លោមួយនៅក្នុងសហរដ្ឋអាមេរិក។

មន្ទីរពិគ្រោះយោបល់ផ្នែកថែទាំសុខភាព នឹងធ្វើប្រតិបត្តិការ ព្រមទាំងគ្រប់គ្រងដោយឯករាជ្យ ជាមួយនឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដទៃទៀត ជាពិសេសគឺគ្រឹះស្ថានការងារសង្គមកិច្ច និងថែទាំសុខភាពផ្លូវចិត្ត។ មន្ទីរពិគ្រោះផ្នែកថែទាំសុខភាពនេះ នឹងផ្តល់ជាទីតាំងមួយដល់គ្រឹះស្ថានសុខភាពផ្លូវចិត្ត និងសង្គមកិច្ចនានាសម្រាប់វិសាលគមយ៉ាងទូលាយមួយ ចាប់ពីកម្រិតគ្រហស្ថរហូតដល់គ្រឹះស្ថានសាសនានានា ដែលផ្តល់នូវអ្នកប្រឹក្សាស្ម័គ្រចិត្ត និងសេវាកម្មសុខភាពសង្គមដទៃទៀត។ វេជ្ជបណ្ឌិត ដេមី រ៉េយស៍ ជាគ្រិស្តបរស័ទមួយរូប និងជាគ្រូពេទ្យភីលីពីនផ្នែកវះកាត់ជុំសាច់និងមហារីក ព្រមទាំង បណ្ឌិត កេសារ៉ា ចាន ទទួលបានសញ្ញាប័ត្របណ្ឌិតផ្នែកសរីរៈមនុស្សពីប្រទេសស្វីស នឹងគ្រប់គ្រងលើការងារនេះ ដោយធ្វើការផ្សារភ្ជាប់ជាមួយនឹងគ្រឹះស្ថានដទៃទៀតនៅក្នុងប្រទេស។ គោលដៅចម្បងនៃមន្ទីរពិគ្រោះនេះ គឺដើម្បីប្រើប្រាស់ការងារស្ម័គ្រចិត្តនានាដែលសម្រេចបានរួចមកហើយនៅក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងទទួលបានការរួបរួមមួយឆ្ពោះទៅរកការធ្វើឲ្យប្រសើរឡើងនូវសុខភាពផ្លូវចិត្ត និងសង្គមរបស់ជនរងគ្រោះ។

បន្ថែមពីលើសេវាកម្មទាំងនេះ ប្រសិនបើជំនួយឧបត្ថម្ភអនុញ្ញាត មន្ទីរពិគ្រោះយោបល់ផ្នែកថែទាំសុខភាពនេះនឹងដាក់ចេញជាគម្រោងគាំពារសុខភាពមួយ។ វេជ្ជបណ្ឌិត ដេមី រ៉េយស៍ ដែលជាអ្នកជំនាញវះកាត់ជុំសាច់ទទួលបានការបណ្តុះបណ្តាលនៅសហរដ្ឋអាមេរិក នឹងមើលការខុសត្រូវលើកិច្ចខិតខំប្រឹងប្រែងនេះ។ គម្រោងនេះនឹងផ្តល់នូវកញ្ចប់សេវាកម្មគាំពារសុខភាព និងការព្យាបាលនៅក្នុងកម្រិតជាក់លាក់មួយ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យបណ្តឹងឧក្រិដ្ឋកម្មទាំង១៧៥០នាក់។ ក្នុងអំឡុងរយៈពេលមួយឆ្នាំ មន្ទីរពិគ្រោះនេះនឹងធ្វើការវាយតម្លៃលើប្រសិទ្ធភាព និងនិរន្តរភាពនៃគម្រោងមួយដែលផ្តល់សេវាកម្មថែទាំសុខភាពបឋម។ គម្រោងនេះមានសារៈសំខាន់ក្នុងការបញ្ជាក់អំពីការធ្វើឲ្យប្រសើរឡើងនូវការរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាងនេះទៅទៀត លើឥទ្ធិពលជារួម ពោលគឺប្រសិទ្ធភាព និងប្រសិទ្ធផលរបស់ដំណើរការនៃគម្រោងសំណងរបស់តុលាការខ្មែរក្រហម។ ដំណើរការនៃគម្រោងសំណងរបស់តុលាការខ្មែរក្រហម ត្រូវទទួលរងការរិះគន់ចំពោះការប្រព្រឹត្តទៅខុសពី និងមិនឆ្លើយតបចំពោះសកម្មភាព និងគម្រោងដែលចាត់ចូលជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។គម្រោងនេះនឹងផ្តល់ឱកាសក្នុងការវាយតម្លៃអំពីប្រសិទ្ធភាពនិងនិរន្តភាពនៃសេវាកម្មសុខភាពបឋមផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលប្រឈមនឹងការលំបាក ក្នុងការទទួលបានសេវាកម្មសុខភាពបឋមបំផុត។

# សេចក្តីសន្និដ្ឋាន

ក្នុងឋានៈជាសង្គមក្រោយជម្លោះចំណាស់មួយ សង្គមស៊ីវិលត្រូវតែធ្វើការផ្លាស់ប្តូរ។ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមើលមើលនូវអន្តរកាលថ្មីមួយនៅក្នុងប្រទេសកម្ពុជាពី "ទឹកដីនៃវាលពិឃាត" ទៅកាន់អ្វីដែលប្រសើរជាងនេះ។ ប្រទេសកម្ពុជាមិនអាចគេចវេះពីអតីតកាលរបស់ខ្លួនឯងបានទេ។ ប្រវត្តិសាស្ត្របន្ថែមពណ៌ លើបច្ចុប្បន្នភាពរបស់យើង ព្រមទាំងអាចទស្សទាយអំពីអនាគតរបស់យើងទៀតផង។ ក៏ប៉ុន្តែ យើងមានជម្រើស។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថាប្រទេសកម្ពុជាត្រៀមខ្លួនជាស្រេច ក្នុងការផ្លាស់ប្តូរទៅកាន់ភាពដែលកាន់តែប្រសើរឡើង។ យើងក៏រំពឹងទៅមុខចំពោះការចូលរួមនៅក្នុងបុព្វហេតុនេះ ព្រមទាំងកសាងនូវអនាគតដ៏ប្រសើរមួយសម្រាប់ប្រទេសជាតិ តំបន់ និងពិភពលោក។

យើងខ្ញុំសូមអរគុណចំពោះជំនួយជាច្រើនសន្ធឹកសន្ធាប់ដែលម្ចាស់ជំនួយអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ និងបន្តផ្តល់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រជាជនកម្ពុជា នៅក្នុងដំណើរការស្វែងរកយុត្តិធម៌ និងការចងចាំ។

មជ្ឈមណ្ឌលឯកសារកម្ពុជា
ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ + ៨៥៥ (០)២៣ ២១០ ៣៥៨

www.d.dccam.org | www.cambodiatribunal.org | www.cambodiasri.org

រូបនៅលើក្រប៖ ផែនទីមួយផ្ទាំងគូរក្នុងឆ្នាំ១៩១៥ បញ្ជាក់អំពីការបះបោរ ដែលកើតមានឡើងនៅផ្នែកឦសាននៃប្រទេសកម្ពុជា នៅក្នុង ឬក្បែរភូមិអូរព្រះ ក្នុងអំឡុងអាណានិគមបារាំងកាន់អំណាច។ ប្រជាជនភាគច្រើននៅក្នុងតំបន់នេះ គឺជាជនជាតិភាគតិចភ្នង និងប្រជាជនដែលសេសសល់គឺជាជនជាតិភាគតិចផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា។ មនុស្សចំនួនដប់ពីរនាក់បានបាត់បង់ជីវិតក្នុងអំឡុងពេលនៃការបះបោរនេះ ទន្ទឹមនឹងនេះក៏មានទាហានបារាំង ដែលត្រូវបានគេសម្លាប់ដែរ។ សព្វថ្ងៃ ភូមិមួយក្នុងចំណោមភូមិនានា ដែលឧបត្តិហេតុនេះកើតឡើង ត្រូវបានដាក់ឈ្មោះថា ភូមិបារាំងងាប់។
*ប្រភព៖ បណ្ណសារដ្ឋានជាតិកម្ពុជា។ ការពិពណ៌នា និងរូបថត៖ អ៊ុំ មករា*



ទេសភាពមួយ ថតពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
*ប្រភព៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា/ អ៊ូច មករា។*